**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ៩២៣ មស.រប

ថ្ងៃ ពុធ ១១កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០២១

**ជម្រាបជូន**
**ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ ៖** សំណើ ផ្តល់ជាបន្ទាន់នូវស្ថិតិ ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា កំពុងបម្រើការងារតាម អង្គភាពចំណុះរដ្ឋបាលរាជធានី ខេត្ត ដែលមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩។

**យោង ៖** ប្រសាសន៍ណែនាំជាបន្ទាន់ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត ជ្រាបថា ដើម្បីអនុវត្តប្រសាសន៍ណែនាំជាបន្ទាន់ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងមុខងារសាធារណៈ សូមស្នើដល់ ឯកឧត្តម លោកជំទាវ អភិបាល រាជធានី ខេត្ត ផ្តល់ជាបន្ទាន់នូវស្ថិតិក្រុមប្រឹក្សា ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាដែលកំពុងបម្រើការងារនៅតាម អង្គភាពចំណុះរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ដែលមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ គិតត្រឹមថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ (លើកលែងតែកងទ័ព នគរបាល គ្រូពេទ្យ និងគ្រូបង្រៀន) មកក្រសួងមុខងារសាធារណៈឱ្យបានមុនម៉ោង៣:០០ នាទីរសៀល នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ នេះ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត ចាត់នាយករដ្ឋបាល ប្រធានមន្ទីរសុខាភិបាល និងប្រធានមន្ទីរមុខងារសាធារណៈសហការគ្នា ដើម្បីស្រង់ស្ថិតិ តាមគំរូបញ្ជីជូនភ្ជាប់ជាមួយនេះ រួចផ្ញើជាបន្ទាន់មកក្រសួងមុខងារសាធារណៈដើម្បីធ្វើការសរុបគោរពផ្ញើជូន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ឲ្យបានទាន់ពេលវេលា។

សូមធ្វើការទំនាក់ទំនងតាមរយៈ Telegram/ទូរស័ព្ទ លោក សោម សារ៉េត 015 21 44 44 លោក ម៉េង ម៉ង់ទិត 017 89 82 58 និងលោក ណែត វ៉ាន់ស៊ីថា 070 67 64 03។

សូម ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**រដ្ឋមន្ត្រី**

ព្រុំ សុខា

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
  "ដើម្បីគោរពជូនជ្រាប"
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- មន្ទីរសុខាភិបាល និងមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ផ្លូវវេត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

# បញ្ជីមន្ត្រីរាជការថ្នាក់ក្រោមជាតិដែលមិនទាន់បានទទួលវ៉ាក់សាំងបង្ការ កូវីដ-១៩

(មិនរាប់បញ្ចូល កងទ័ព នគរបាល គ្រូបង្រៀន និងគ្រូពេទ្យ)

| លេខរៀង | រាជធានីខេត្ត | ចំនួនមន្ត្រី | | ចំនួនមន្ត្រីដែលបានចាក់រួចហើយ | ចំនួនមន្ត្រីដែលមិនទាន់បានចាក់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | មន្ត្រីក្របខ័ណ្ឌ | មន្ត្រីកិច្ចសន្យា | | | |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |